# គោលនយោបាយជំនួយហិរញ្ញវត្ថុរបស់ Brown University Health - សេចក្តីសង្ខេបជាភាសាសាមញ្ញ

គោលនយោបាយជំនួយហិរញ្ញវត្ថុរបស់ Brown University Health ផ្តល់ជូនអ្នកជំងឺដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់នូវការបញ្ចុះតម្លៃខ្លះ ឬទាំងស្រុងលើសេវាថែទាំសុខភាពបន្ទាន់ និងសេវាថែទាំសុខភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រផ្សេងទៀត ដែលផ្តល់ដោយសាខារបស់ Brown University Health។ សាខាទាំងនេះរួមមាន Rhode Island Hospital, The Miriam Hospital, Newport Hospital, Emma Pendleton Bradley Hospital (Bradley Hospital), Lifespan Physician Group, Inc. DBA Brown Health Medical Group, Gateway Healthcare, Inc., Coastal Medical Physicians, Inc DBA Brown Health Medical Group, Primary Care. និងអង្គភាពពាក់ព័ន្ធសំខាន់ៗណាមួយដែលបន្តបន្ទាប់ពីនេះ ត្រូវហៅកាត់ថា Brown University Health។ អ្នកជំងឺដែលស្វែងរកជំនួយហិរញ្ញវត្ថុត្រូវតែដាក់ពាក្យស្នើសុំចូលរួមក្នុងកម្មវិធីនេះ។ ព័ត៌មានលម្អិតអំពីគោលនយោបាយ និងដំណើរការនៃការដាក់ពាក្យស្នើសុំត្រូវបានសង្ខេបនៅក្នុងទីនេះ។

សេវាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់៖ សេវាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ រួមមានសេវាដែលផ្តល់ និងចេញវិក្កយបត្រដោយ Brown University Health រួមមានជាអាទិ៍ ការថែទាំសង្គ្រោះបន្ទាន់ និងសេវាវេជ្ជសាស្ត្រចាំបាច់ ដល់អ្នកជំងឺដែលគ្មានការធានារ៉ាប់រង អ្នកដែលមានការធានារ៉ាប់រងមិនគ្រប់គ្រាន់ អ្នកដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីអត្ថប្រយោជន៍ថែទាំសុខភាពរបស់រដ្ឋាភិបាលណាមួយ និងអ្នកដែលមិនមានលទ្ធភាពបង់ថ្លៃសេវាថែទាំសុខភាពរបស់ពួកគេ។ សូមជម្រាបថា FAP អនុវត្តចំពោះតែសេវាដែលចេញវិក្កយបត្រដោយ Brown University Health ប៉ុណ្ណោះ។ សេវាផ្សេងទៀតដែលចេញវិក្កយបត្រដាច់ដោយឡែកដោយអ្នកផ្តល់សេវាផ្សេងទៀត ដូចជាគ្រូពេទ្យ ឬមន្ទីរពិសោធន៍ដែលមិនពាក់ព័ន្ធជាមួយ Brown University Health គឺមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្រោម FAP ឡើយ។

ការគណនានៃការបញ្ចុះតម្លៃ

អ្នកជំងឺដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ជំនួយហិរញ្ញវត្ថុក្រោមកម្មវិធីជំនួយហិរញ្ញវត្ថុ (Financial Assistance Program (FAP)) នឹងមិនទទួលបានវិក្កយបត្រគិតថ្លៃលើសពី "ចំនួនទឹកប្រាក់ដែលត្រូវបានចេញវិក្កយបត្រជាទូទៅ" (AGB) ឡើយ។ Brown University Health ប្រើប្រាស់វិធីសាស្ត្រតាមការរំពឹងទុកក្នុងការកំណត់ AGB ដែលត្រូវបានកំណត់ដោយក្រមចំណូលផ្ទៃក្នុង ផ្នែកលេខ §501(r) ថាជាចំនួនទឹកប្រាក់ដែល Medicare ឬ Medicaid នឹងផ្តល់សំណងដល់មន្ទីរពេទ្យសម្រាប់ការថែទាំដែលបានចេញវិក្កយបត្រ (រួមទាំងចំនួនទឹកប្រាក់ដែលនឹងត្រូវផ្តល់សំណងដោយ Medicare ឬ Medicaid និងចំនួនទឹកប្រាក់ដែលអ្នកទទួលផលនឹងត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនក្នុងការបង់ក្នុងទម្រង់ជាការបង់ប្រាក់រួម ការធានារ៉ាប់រងរួម និងការកាត់កង) ប្រសិនបើអ្នកជំងឺគឺជាអ្នកទទួលផលពីការគិតថ្លៃតាមសេវារបស់ Medicare ឬ Medicaid។ ការគណនា AGB ជាក់លាក់សម្រាប់មន្ទីរពេទ្យ Brown University Health នីមួយៗដែលស្ថិតក្រោម FAP មានរាយបញ្ជីដូចខាងក្រោម៖

- អ្នកជំងឺដែលគ្មានការធានារ៉ាប់រង និងអ្នកដែលមានការធានារ៉ាប់រង ដែលត្រូវបានអនុម័តឱ្យទទួលបានជំនួយហិរញ្ញវត្ថុ ហើយដែលមានកម្រិតចំណូលស្ថិតនៅក្រោម 201% នៃគោលការណ៍ណែនាំស្តីពីភាពក្រីក្ររបស់សហព័ន្ធនឹងទទួលបានការបញ្ចុះតម្លៃសេវាឥតគិតថ្លៃក្នុងសហគមន៍ 100% សម្រាប់សេវាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។ ការបញ្ចុះតម្លៃនេះនឹងធ្វើឱ្យគ្មានសមតុល្យទឹកប្រាក់ដែលនៅសល់សម្រាប់សេវាដែលបានទទួលឡើយ។

- អ្នកជំងឺដែលគ្មានការធានារ៉ាប់រង ដែលត្រូវបានអនុម័តឱ្យទទួលបានជំនួយហិរញ្ញវត្ថុ ហើយដែលមានកម្រិតចំណូលស្ថិតក្នុងចន្លោះ 201%-300% នៃគោលការណ៍ណែនាំស្តីពីភាពក្រីក្ររបស់សហព័ន្ធ នឹងទទួលបានការកែសម្រួលជំនួយហិរញ្ញវត្ថុផ្នែកខ្លះលើសេវាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់៖
    i. អ្នកជំងឺសម្រាកព្យាបាល៖ បញ្ចុះតម្លៃ 80% នៃ DRG ដែលអាចចេញវិក្កយបត្របាន
    ii. អ្នកជំងឺមិនសម្រាកព្យាបាល៖ បញ្ចុះតម្លៃ 90% នៃថ្លៃសរុប
- អ្នកជំងឺដែលមានការធានារ៉ាប់រង ដែលត្រូវបានអនុម័តឱ្យទទួលបានជំនួយហិរញ្ញវត្ថុ ហើយដែលមានកម្រិតចំណូលស្ថិតក្នុងចន្លោះ 201%-300% នៃគោលការណ៍ណែនាំស្តីពីភាពក្រីក្ររបស់សហព័ន្ធ នឹងទទួលបានការកែសម្រួលជំនួយហិរញ្ញវត្ថុខ្លះលើសេវាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។
- អ្នកជំងឺដែលគ្មានការធានារ៉ាប់រង ដែលមិនត្រូវបានអនុម័តឱ្យទទួលបានជំនួយហិរញ្ញវត្ថុ នឹងទទួលបានការបញ្ចុះតម្លៃសម្រាប់អ្នកបង់ប្រាក់ដោយផ្ទាល់ដែលគ្មានការធានារ៉ាប់រងដែលមានចែងក្នុងតារាង 1-B។
- អ្នកជំងឺដែលមានការធានារ៉ាប់រង ដែលទទួលបានសេវាកម្មមិនគ្របដណ្តប់ពីគ្លីនិកសុខភាពផ្លូវចិត្តសហគមន៍ដែលបានបញ្ជាក់របស់ Gateway នឹងមានលក្ខណសម្បត្តិគ្រប់គ្រាន់ទទួលបានការបញ្ចុះតម្លៃសម្រាប់អ្នកគ្មានការធានារ៉ាប់រងដែលមានចែងក្នុងតារាង 1-B។

កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការបញ្ចុះតម្លៃ៖ 10/1/2025។

Brown University Health ធ្វើបច្ចុប្បន្នភាពការបញ្ចុះតម្លៃសម្រាប់អ្នកគ្មានការធានារ៉ាប់រងជារៀងរាល់ឆ្នាំនៅថ្ងៃទី 1 ខែតុលា។ សម្រាប់ភាគរយនៃការបញ្ចុះតម្លៃសម្រាប់ឆ្នាំមុនៗ សូមទាក់ទងសេវាហិរញ្ញវត្ថុអ្នកជំងឺតាមរយៈលេខ 401-444-6966។

| តារាង៖ 1-B<br>មន្ទីរពេទ្យ/ក្រុមគ្រូពេទ្យ | វិធីសាស្ត្រតាមការរំពឹងទុក | អ្នកជំងឺសម្រាកព្យាបាល | អ្នកជំងឺមិនសម្រាកព្យាបាល |
|---|---|---|---|
| មន្ទីរពេទ្យ Emma Pendleton Bradley Hospital | Medicaid | 46% | 70% |
| Lifespan Physician Group, Inc. មានឈ្មោះអាជីវកម្មជា Brown Health Medical Group | គ្មាន | 74% | 74% |

| | | | |
|---|---|---|---|
| Lifespan Physician Group, Inc. មានឈ្មោះអាជីវកម្មជា Brown University Health Urgent Care | គ្មាន | គ្មាន | 50% |
| Gateway Healthcare, Inc. | គ្មាន | គ្មាន | 54% |
| Radiosurgery Center of Rhode Island, LLC. | គ្មាន | គ្មាន | 78% |
| មន្ទីរពេទ្យ Rhode Island Hospital | Medicare | DRG* | 78% |
| Samuel Sinclair Dental Center (RIH) | គ្មាន | គ្មាន | 50% |
| មន្ទីរពេទ្យ Newport Hospital | Medicare | DRG* | 82% |
| មន្ទីរពេទ្យ The Miriam Hospital | Medicare | DRG* | 80% |
| Coastal Medical Physicians, Inc មានឈ្មោះអាជីវកម្មជា Brown Health Medical Group Primary Care | គ្មាន | គ្មាន | 47% |

ការបញ្ចុះតម្លៃគឺផ្អែកលើកាលបរិច្ឆេទដែលសេវាកម្មត្រូវបានផ្តល់ជូន។ សម្រាប់ការសម្រាកព្យាបាលដែលមានរយៈពេលច្រើនថ្ងៃ Brown University Health នឹងប្រើប្រាស់កាលបរិច្ឆេទចូលសម្រាកព្យាបាលនៅពេលកំណត់ភាគរយនៃការបញ្ចុះតម្លៃ។

*ការបញ្ចុះតម្លៃ DRG នឹងត្រូវអនុវត្តដោយកាត់បន្ថយការគិតថ្លៃសរុបមកត្រឹមចំនួនទឹកប្រាក់ DRG របស់ Medicare។ (សូមមើលនិយមន័យ DRG នៅក្នុងសទ្ទានុក្រម)

ព័ត៌មានលម្អិតអំពីអត្រា FPG ឆ្នាំ 2024 ត្រូវបានបង្ហាញនៅក្នុងច្បាប់ពេញលេញនៃ FAP របស់ Brown University Health ដែលមានផ្តល់ជូន។

របៀបដាក់ពាក្យស្នើសុំ៖ គោលការណ៍ FAP របស់ Brown University Health និងទម្រង់បែបបទពាក្យសុំដែលពាក់ព័ន្ធអាចទទួលបាន បំពេញ និងដាក់ជូនតាមវិធីដូចខាងក្រោម៖

ឯកសារ FAP និងពាក្យសុំរបស់ Brown University Health មានផ្តល់ជូនដោយផ្ទាល់នៅតាមទីតាំងអគារមន្ទីរពេទ្យ Brown University Health ដូចខាងក្រោម៖

- Rhode Island Hospital, Patient Advocate Office, 593 Eddy Street, Providence, RI 02903
- The Miriam Hospital, Patient Advocate Office, 164 Summit Avenue, Providence, RI 02906
- Newport Hospital, Patient Advocate Office, 11 Friendship Street, Newport, RI 02840
- Bradley Hospital, Patient Financial Services, 1011 Veterans Memorial Parkway, East Providence, RI 02915

ឯកសារជំនួយហិរញ្ញវត្ថុរបស់ *Brown University Health* ក៏មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈការស្នើសុំតាមប្រៃសណីយ៍ ដោយប្រើប្រាស់អាសយដ្ឋានអគារមន្ទីរពេទ្យណាមួយដែលមានរាយបញ្ជីខាងលើ។ អ្នកជំងឺអាចចូលទៅកាន់គេហទំព័រ https://www.brownhealth.org/patients-visitors/insurance-billing-and-financial-assistance/financial-assistance ដើម្បីទទួលបានព័ត៌មាន និងទម្រង់ចាំបាច់ទាំងអស់។ ការស្នើសុំផ្ញើឯកសារតាមប្រៃសណីយ៍អាចធ្វើឡើងបានតាមរយៈការទូរសព្ទទៅកាន់ការិយាល័យសេវាហិរញ្ញវត្ថុអ្នកជំងឺរបស់ Brown University Health តាមរយៈលេខ (401) 444-6949។ *អ្នកជំងឺដែលមានគណនី MyChart សកម្មអាចដាក់ពាក្យសុំកម្មវិធីជំនួយហិរញ្ញវត្ថុតាមអនឡាញតាមគេហទំព័រ* https://www.brownhealth.org/mylifespan

ផ្ញើពាក្យសុំដែលបានបំពេញរួចតាមប្រៃសណីយ៍ ឬយកទៅប្រគល់ជូនដោយផ្ទាល់ (ជាមួយឯកសារ/ព័ត៌មានទាំងអស់ដែលមានបញ្ជាក់ក្នុងសេចក្តីណែនាំនៃពាក្យសុំ) ទៅកាន់អាសយដ្ឋានអគារមន្ទីរពេទ្យណាមួយរបស់ Brown University Health ដែលមានរាយបញ្ជីខាងលើ។

Brown University Health បកប្រែគោលការណ៍ FAP ទម្រង់បែបបទពាក្យសុំ FAP និងសេចក្តីសង្ខេបជាភាសាសាមញ្ញនៃ FAP របស់ខ្លួន ជាភាសាគោលនៃក្រុមប្រជាជនដែលមានកម្រិតចំណេះដឹងភាសាអង់គ្លេសមានកំណត់ ដែលមានចំនួន 5% ឬ 1,000 នាក់នៃអ្នករស់នៅក្នុងសហគមន៍ដែលបម្រើដោយបរិក្ខារមន្ទីរពេទ្យ។ ព័ត៌មានទាំងអស់អាចរកបានតាមអនឡាញតាមគេហទំព័រ https://www.brownhealth.org/patients-visitors/insurance-billing-and-financial-assistance/financial-assistance -ឬនៅតាមអគារមន្ទីរពេទ្យ Brown University Health ដែលបានរាយបញ្ជីពីមុន។

សម្រាប់ជំនួយបន្ថែម ឬសំណួរផ្សេងៗ សូមទូរសព្ទទៅកាន់ការិយាល័យទទួលអ្នកជំងឺ-អ្នកតស៊ូមតិអ្នកជំងឺតាមរយៈលេខ 401-444-7850។ ប្រសិនបើមកដោយផ្ទាល់ សូមអញ្ជើញមកកាន់ទីតាំងអគារមន្ទីរពេទ្យ Brown University Health ណាមួយដែលមានរាយបញ្ជីខាងលើ ចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 4:00 ល្ងាច ថ្ងៃចន្ទដល់ថ្ងៃសុក្រ។